## គម្រោង PCR SR-KCM រៀបចំទស្សនៈកិច្ចសិក្សាចំនួនពីរទៅកាន់ខេត្តព្រៃវែង

ពីថ្ងៃទី ១៤ ដល់ទី ១៧ ខែមិថុនាឆ្នាំ ២០១១ គំរោង **"កែលម្អ កម្រិតជីវភាពគ្រួសារកសិករក្រីក្រ ដើម្បីអោយមានភាពបន្សាំ ទៅនឹងការប៉ះប្រែប្រួល អាកាសធាតុនៅតំបន់ជីស្ងួត ក្នុងខេត្ត សៀមរាប និងកំពង់ចាម"** បានរៀបចំទស្សនៈកិច្ចសិក្សាចំនួនពីរជូនដល់ក្រុមកសិករចំនួន ១៣៥នាក់ មកពីឃុំចំនួន ៧ ក្នុងស្រុកដំបែរ ដើម្បីស្វែងយល់ និងសិក្សាអំពីការអនុវត្តន៏កសិកម្មប្រកបដោយនិរន្តរភាព របស់កសិករ ដែលបានសហការជាមួយអង្គការសេដាក នៅក្នុងខេត្តព្រៃវែង ។ គោល បំណងសំខាន់គឺ ដើម្បីបង្កើនទំនុកចិត្តរបស់កសិករ ក្នុងការអនុវត្តន៏នូវ បច្ចេកទេសកសិកម្មប្រកបដោយនិរន្តរភាពផ្សេងៗ ពិសេសគឺការបង្កើន ជីរជាតិដី ការដាំដើមឈើ ការចិញ្ចឹមមាន ត្រី កសិដ្ឋានពហុប្រយោជន៏ និងប្រពលវប្បកម្មស្រូវ ។

